សេចក្តីប្រកាសព័ត៌មាន

រដ្ឋមន្ត្រីក្រសួងការបរទេសនិងពាណិជ្ជកម្ម
លោកជំទាវ **The Hon Julie Bishop MP**

**ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧**

# ស្ថានភាពនយោបាយនៅកម្ពុជា

អូស្ត្រាលីមានក្តីបារម្ភយ៉ាងខ្លាំងចំពោះការរំលាយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំរបស់កម្ពុជា និងការហ៊ាមឃាត់ការព្យួរសិទ្ធិនយោបាយរយៈពេលប្រាំឆ្នាំដល់មន្ត្រី និងតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។

ការវិវត្តនេះជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ សកម្មភាពនេះជាស្ថានភាពដ៏អាក្រក់ដល់កំពូលក្នុងចំណោមសកម្មភាពដ៏យ៉ាប់យឺនជាបន្តបន្ទាប់ រួមមានការកាត់បន្ថយសេរីភាពសារព័ត៌មាន ការរឹតត្បឹតលើអង្គការសង្គមស៊ីវិល និងការគំរាមកំហែងលើសម្លេងប្រឆាំង ជាពិសេសគឺការឃុំខ្លួនប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា។

ប្រជាពលរដ្ឋកម្ពុជាប្តេជ្ញាចំពោះលទ្ធិប្រជាធិបតេយ្យ ដូចបានបង្ហាញតាមរយៈការចូលរួមទៅបោះឆ្នោតដ៏ច្រើនកុះករ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីពេលកន្លងទៅ។ ការរំលាយគណបក្សសង្គ្រោះជាតិមានន័យថាសម្លេងឆ្នោតដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងការបោះឆ្នោតនោះនឹងលែងត្រូវបានទទួលស្គាល់។

ក្នុងនាមជាមិត្តភក្តិរបស់កម្ពុជា អូស្ត្រាលីសូមជំរុញដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យអនុញ្ញាតិប្រជាពលរដ្ឋគ្រប់រូបនូវឱកាសក្នុងការអនុវត្តនូវសិទ្ធិប្រជាធិបតេយ្យ ជាពិសេសក្នុងអំឡុងពេលឈានទៅដល់ការបោះឆ្នោតជាតិឆ្នាំ២០១៨។